KB PRASAC Bank

ធនាគារ ខេប៊ីប្រាសាក់ ម.ក

លក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណឌីជីថល

Terms & Conditions of Using the Virtual Card

ចោះពុម្ពលើកទី ២

មាតិកា

1. សេចក្តីផ្តើម 1
2. និយមន័យ 1
3. ប្រភេទប័ណ្ណនិម្មិត 1
4. មធ្យោបាយបង្កើតប័ណ្ណនិម្មិត 2
5. រូបិយប័ណ្ណគណនីទូទាត់ភ្ជាប់ប័ណ្ណនិម្មិត 2
6. ចំនួនគណនីភ្ជាប់ប័ណ្ណនិម្មិត 2
7. រយៈពេលបង្កើតប័ណ្ណនិម្មិត 2
8. សុពលភាពប័ណ្ណនិម្មិត 2
9. ចំនួនប័ណ្ណនិម្មិត 2
10. ទំហំទឹកប្រាក់ និងចំនួនប្រតិបត្តិការ 2
11. ម៉ោងប្រតិបត្តិការ 2
12. រូបិយប័ណ្ណ និងអត្រាប្តូរប្រាក់ 2
13. ប្រតិបត្តិការលើប័ណ្ណនិម្មិត 3
14. កម្រៃសេវា 3
15. ការកែប្រែកម្រៃសេវា ទំហំទឹកប្រាក់ធ្វើប្រតិបត្តិការ ចំនួនប្រតិបត្តិការ លក្ខខណ្ឌផ្សេងៗ និងការជូនដំណឹង 3
16. ការបង្ខាំង ឬ ដោះបង្ខាំងប័ណ្ណនិម្មិត 3
17. ការស្នើសុំបិទប័ណ្ណនិម្មិត 4
18. សុវត្ថិភាពនៃការប្រើប្រាស់ប័ណ្ណនិម្មិត 4
    18.1. ការគ្រប់គ្រងព័ត៌មានប័ណ្ណនិម្មិត និងការធ្វើប្រតិបត្តិការ៖ 4
    18.2. សារបោកបញ្ឆោតតាមរយៈអ៊ីម៉ែល ឬ ទូរស័ព្ទ៖ 4
19. ការដោះស្រាយវិវាទលើប្រតិបត្តិការប័ណ្ណនិម្មិត 5
20. សិទ្ធិ និងកាតព្វកិច្ចរបស់លោក-លោកស្រី 5
21. សិទ្ធិ និងកាតព្វកិច្ចរបស់ខេប៊ីប្រាសាក់ 6
22. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម 7
23. ច្បាប់គ្រប់គ្រង 7
24. ស្វ័យភាពនៃបញ្ញត្តិ 7

1. សេចក្តីផ្តើម

លក្ខខណ្ឌនៃការប្រើប្រាស់បណ្ណនិម្មិត របស់ធនាគារ ខេប៊ីប្រាសាក់ ម.ក តទៅហៅថា **«លក្ខខណ្ឌប្រើប្រាស់»** គឺជាកិច្ចព្រមព្រៀងរវាង **លោក-លោកស្រី** ជាមួយ ធនាគារ ខេប៊ីប្រាសាក់ ម.ក តទៅហៅថា **«ខេប៊ីប្រាសាក់»** ទាក់ទងទៅនឹងការបង្កើត និងប្រើប្រាស់បណ្ណនិម្មិត តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

នៅពេល លោក-លោកស្រី ចុចលើពាក្យ **«យល់ព្រម»** មានន័យថា លោក-លោកស្រី បានអាន បានយល់ និងព្រមអនុវត្តតាមគ្រប់លក្ខខណ្ឌ ដែលមានចែងនៅក្នុង **«លក្ខខណ្ឌនៃការប្រើប្រាស់និម្មិត»** នេះ។

2. និយមន័យ

- ❖ **លោក-លោកស្រី** ៖ សំដៅលើអតិថិជនដែលជាម្ចាស់គណនី និងជាអ្នកដែលបានបង្កើត និងប្រើប្រាស់បណ្ណនិម្មិត។
- ❖ **ខេប៊ីប្រាសាក់** ៖ សំដៅលើ ធនាគារ ខេប៊ីប្រាសាក់ ម.ក ដែលជាអ្នកចេញបណ្ណនិម្មិត ជូន លោក-លោកស្រី។
- ❖ **បណ្ណនិម្មិត** ៖ ជាបណ្ណឥណពន្ធអេឡិចត្រូនិក និងមិនមានរូបរាងជាបណ្ណប្លាស្ទិក (មិនអាចកាន់ ឬ ប៉ះបាន) ដោយអតិថិជនអាចធ្វើការបង្កើតបានភ្លាមៗដោយខ្លួនឯងតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល (KB PRASAC Mobile) ប្រើប្រាស់ដើម្បីធ្វើការទូទាត់ទំនិញ/សេវាកម្មតាមអនឡាញ (Online)។ អតិថិជនអាចមើលឃើញនូវព័ត៌មានបណ្ណនិម្មិតដែលខ្លួនបានបង្កើតរួមមាន លេខប័ណ្ណ លេខកូដ CVV និងកាលបរិច្ឆេទផុតសុពលភាពតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។
- ❖ **ការទូទាត់ទំនិញ/សេវាកម្មតាមអនឡាញ** ៖ គឺជាការទូទាត់ថ្លៃទំនិញ/សេវាកម្មតាមរយៈប្រព័ន្ធអេឡិចត្រូនិក ដូចជា តាមរយៈវេបសាយត៍ផ្លូវការធំៗ ឬ កម្មវិធី (App) ទិញទំនិញ/សេវាកម្មរបស់ពាណិជ្ជករ/អាជីវករ (ឧ. Amazon, Taobao, Ebay, AliExpress, Lazada, Food Panda...) ដែលមានស្លាកសញ្ញា **វីសា (VISA)** ។
- ❖ **ប្រធានសក្តិ** ៖ សំដៅលើអំពើទាំងឡាយណា ដែលកើតឡើងក្រៅពីឆន្ទៈ ដោយមិនអាចប៉ាន់ស្មានជាមុន និងមិនអាចជំនះបាន ឬ ដែលមិនអនុញ្ញាតឱ្យភាគីណាមួយ ឬ ទាំងពីរអាចបន្តបំពេញកាតព្វកិច្ចរបស់ខ្លួនជាប្រក្រតីបានដូចជា៖ បន្ទុះភ្នំភ្លើង ទឹកជំនន់ គ្រោះរញ្ជួយដី ព្យុះសង្ឃរា ភេរវកម្ម កុបកម្ម សង្គ្រាម។ល។
- ❖ **វីសា** | VISA ៖ សំដៅដល់ក្រុមហ៊ុន Visa Inc., ដែលជាក្រុមហ៊ុនផ្តល់សេវាទូទាត់តាមប្រព័ន្ធអេឡិកត្រូនិកជុំវិញសាកលលោកជាមួយនឹងបណ្ណឥណទាន បណ្ណឥណពន្ធ បណ្ណ prepaid cards និងប្រភេទបណ្ណផ្សេងទៀងដែលមានស្លាកសញ្ញា VISA។

3. ប្រភេទបណ្ណនិម្មិត

- ជាបណ្ណនិម្មិត របស់ក្រុមហ៊ុនទូទាត់អន្តរជាតិ វីសា (VISA) ។
- ជាបណ្ណឥណពន្ធ (Debit Card) ដែលប្រើប្រាស់ទឹកប្រាក់ផ្ទាល់នៅក្នុងគណនីរបស់ លោក-លោកស្រី សម្រាប់ទូទាត់លើការទិញទំនិញ/សេវាកម្ម។

4. មធ្យោបាយបង្កើតបណ្ណនិម្មិត

លោក-លោកស្រីអាចបង្កើតបណ្ណនិម្មិតបានភ្លាមៗ គ្រប់ពេលវេលា និងគ្រប់ទីកន្លែង តាមរយៈ «កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល (KB PRASAC Mobile)»។

5. រូបិយប័ណ្ណគណនីទូទាត់ភ្ជាប់បណ្ណនិម្មិត

ជាគណនីទូទាត់ដែលមាន រូបិយប័ណ្ណប្រាក់ដុល្លារអាមេរិក (USD) តែមួយគត់។

6. ចំនួនគណនីភ្ជាប់បណ្ណនិម្មិត

6.1. គណនី 1 អាចភ្ជាប់បណ្ណនិម្មិតបានរហូតដល់ចំនួន 05 បណ្ណ។

6.2. លោក-លោកស្រីអាចធ្វើការផ្លាស់ប្តូរគណនីទូទាត់ភ្ជាប់ជាមួយបណ្ណនិម្មិតបានដោយខ្លួនឯងតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

7. រយៈពេលបង្កើតបណ្ណនិម្មិត

បណ្ណត្រូវបានបង្កើតភ្លាមៗ ដោយអតិថិជនផ្ទាល់តាមកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល (KB PRASAC Mobile) ។

8. សុពលភាពបណ្ណនិម្មិត

បណ្ណនិម្មិតមានសុពលភាពប្រើប្រាស់រយៈពេល 02 ឆ្នាំ គិតចាប់ពីថ្ងៃបង្កើតបណ្ណ។

9. ចំនួនបណ្ណនិម្មិត

9.1. លោក-លោកស្រី អាចបង្កើតបណ្ណនិម្មិតចំនួន 05 បណ្ណ តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

9.2. សម្រាប់អតិថិជនជាប្រភេទជូនៀ (Junior) ដែលមានគណនីជូនៀ អាចបង្កើតបណ្ណនិម្មិតបានចំនួន 01 បណ្ណតែប៉ុណ្ណោះ។

10. ទំហំទឹកប្រាក់ និងចំនួនប្រតិបត្តិការ

10.1. ទំហំកំណត់អតិបរមា សម្រាប់ប្រតិបត្តិការបណ្ណក្នុងមួយថ្ងៃ និងក្នុងមួយប្រតិបត្តិការ គឺយោងទៅតាមប្រភេទអតិថិជនដែលបានកំណត់ដោយខេប៊ីប្រាសាក់។

10.2. ចំនួនប្រតិបត្តិការក្នុង 01ថ្ងៃ៖ 30 ប្រតិបត្តិការ សម្រាប់ 01 បណ្ណ។

10.3. លោក-លោកស្រី អាចធ្វើការបន្ថយ ឬ ដំឡើងទំហំប្រតិបត្តិការមកវិញ និង/ឬ ចំនួនប្រតិបត្តិការ បានដោយខ្លួនឯងតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

11. ម៉ោងប្រតិបត្តិការ

លោក-លោកស្រី អាចធ្វើប្រតិបត្តិការបណ្ណនិម្មិតបានជាប្រចាំថ្ងៃ (24/7) លើកលែងតែមានការផ្អាកប្រតិបត្តិការជាបណ្តោះអាសន្នដោយមានការជូនដំណឹងពីខេប៊ីប្រាសាក់។

12. រូបិយប័ណ្ណ និងអត្រាប្តូរប្រាក់

12.1. លោក-លោកស្រី អាចធ្វើប្រតិបត្តិការតាមរយៈបណ្ណនិម្មិត ជាមួយរូបិយប័ណ្ណដុល្លារអាមេរិក (USD) រូបិយប័ណ្ណរៀល (KHR) និងរូបិយប័ណ្ណផ្សេងៗទៀតអាស្រ័យទៅតាមតម្រូវការប្រើប្រាស់ជាក់ស្តែង។

12.2. លោក-លោកស្រី ត្រូវបង់កម្រៃសេវាលើការធ្វើប្រតិបត្តិការខុសពីរូបិយប័ណ្ណគណនី ដូចមានបង្ហាញនៅក្នុងវេបសាយត៍ផ្លូវការ ឬ តាមសាខាខេប៊ីប្រាសាក់ណាមួយ។

12.3. ប្រតិបត្តិការឆ្លងរូបិយប័ណ្ណ ត្រូវយោងតាមអត្រាប្តូរប្រាក់ជាក់ស្តែង របស់ក្រុមហ៊ុនអន្តរជាតិវីសា (VISA) ។

13. ប្រតិបត្តិការលើបណ្ណនិម្មិត

13.1. លោក-លោកស្រីអាចប្រើប្រាស់បណ្ណនិម្មិត ដើម្បីធ្វើប្រតិបត្តិការទូទាត់ទំនិញ/សេវាកម្មតាមអនឡាញបានគ្រប់ពេល នៅពេលដែលគណនីទូទាត់មានសមតុល្យគ្រប់គ្រាន់ និងត្រូវគោរពទៅតាមទំហំកំណត់ដោយ ខេប៊ីប្រាសាក់។

13.2. លោក-លោកស្រី ត្រូវត្រួតពិនិត្យ និងធ្វើឱ្យទាន់គ្រប់ព័ត៌មាននៃប្រតិបត្តិការឱ្យបានត្រឹមត្រូវ និងច្បាស់លាស់មុនពេលសម្រេចអនុម័តប្រតិបត្តិការតាមបណ្ណ។

13.3. លោក-លោកស្រី ត្រូវបង់កម្រៃសេវាផ្សេងៗ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ និង/ឬ ធ្វើប្រតិបត្តិការតាមរយៈបណ្ណ និងយល់ព្រមឱ្យ **ខេប៊ីប្រាសាក់** ទូទាត់កម្រៃសេវាដោយផ្ទាល់ចេញពីគណនីរបស់លោក-លោកស្រីដោយស្វ័យប្រវត្តិ។

14. កម្រៃសេវា

កម្រៃសេវាលើការស្នើសុំបណ្ណនិម្មិត កម្រៃសេវាប្រចាំឆ្នាំ ការស្នើសុំកែប្រែ/មោឃភាពបណ្ណ កម្រៃសេវាលើការធ្វើប្រតិបត្តិការឆ្លងរូបិយប័ណ្ណ និងកម្រៃសេវាលើការធ្វើប្រតិបត្តិការផ្សេងៗ (ទូទាត់ទំនិញ / សេវាកម្ម បញ្ជូន / បង្វិលទឹកប្រាក់ត្រលប់...) គឺមានបង្ហាញនៅលើវេបសាយត៍ផ្លូវការ និង/ឬ គ្រប់សាខាខេប៊ីប្រាសាក់។

15. ការកែប្រែកម្រៃសេវា ទំហំទឹកប្រាក់ធ្វើប្រតិបត្តិការ ចំនួនប្រតិបត្តិការ លក្ខខណ្ឌផ្សេងៗ និងការជូនដំណឹង

15.1. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែ កម្រៃសេវា ទំហំទឹកប្រាក់ធ្វើប្រតិបត្តិការ ចំនួនប្រតិបត្តិការ និង/ឬ លក្ខខណ្ឌផ្សេងៗដែលត្រូវអនុវត្តចំពោះការប្រើប្រាស់បណ្ណនិម្មិត របស់ លោក-លោកស្រី ដោយ ខេប៊ីប្រាសាក់នឹងធ្វើការជូនដំណឹងឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃច្បាប់។

15.2. ក្នុងរយៈពេលនៃការជូនដំណឹងខាងលើ ករណីមិនមានការតវ៉ាពី លោក-លោកស្រី គឺត្រូវសន្មតថា លោក-លោកស្រី យល់ព្រម និងទទួលយកការកែប្រែទាំងនោះមកអនុវត្តភ្លាមៗបន្ទាប់ពីការកែប្រែចូលជាធរមានដែលត្រូវបានផ្សព្វផ្សាយតាមរយៈមធ្យោបាយណាមួយខាងក្រោម៖

1). សាខាខេប៊ីប្រាសាក់ និង/ឬ
2). វេបសាយត៍ និង/ឬ បណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ ខេប៊ីប្រាសាក់ និង/ឬ
3). ការផ្ញើសារ និង/ឬ អ៊ីម៉ែលទៅកាន់ លោក-លោកស្រី
4). ការផ្សព្វផ្សាយនៅលើទំព័រកាសែត ទស្សនាវដ្តី កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ មធ្យោបាយផ្សេងៗ ដែលខេប៊ីប្រាសាក់ បានជ្រើសរើស។ល។

15.3. លោក-លោកស្រីត្រូវបានសន្មតថាបានទទួលការជូនដំណឹងស្តីពីការកែប្រែខាងលើភ្លាមៗ បន្ទាប់ពីខេប៊ីប្រាសាក់បានចុះផ្សាយពីការកែប្រែព័ត៌មាននានារបស់ខ្លួនតាមរយៈមធ្យោបាយណាមួយក្នុងចំណោមមធ្យោបាយខាងលើ។

16. ការបង្ខាំង ឬ ដោះបង្ខាំងបណ្ណនិម្មិត

16.1. លោក-លោកស្រី អាចបង្ខាំងបណ្ណនិម្មិត (Freeze) បានភ្លាមៗ តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ ស្នើសុំតាមរយៈទូរស័ព្ទ ឬ អ៊ីម៉ែលមកមន្ត្រីបម្រើសេវាអតិថិជន (023/086 999 911 / info@kbprasacbank.com.kh) ឬ អញ្ជើញមកកាន់សាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិតបំផុត។

16.2. លោក-លោកស្រី អាចដោះបង្ខាំងបណ្ណនិម្មិត (Unfreeze) បានភ្លាមៗ តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ អញ្ជើញមកកាន់សាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិតបំផុត។

17. ការស្នើសុំបិទបណ្ណនិម្មិត

លោក-លោកស្រី អាចស្នើសុំបិទការប្រើប្រាស់បណ្ណនិម្មិតជាលាយលក្ខណ៍អក្សរនៅតាមសាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិតបំផុត ឬ តាមមធ្យោបាយផ្សេងទៀត ដែលផ្តល់ជូនដោយខេប៊ីប្រាសាក់។

18. សុវត្ថិភាពនៃការប្រើប្រាស់បណ្ណនិម្មិត

18.1. ការគ្រប់គ្រងព័ត៌មានបណ្ណនិម្មិត និងការធ្វើប្រតិបត្តិការ៖

18.1.1. មិនត្រូវយកបណ្ណនិម្មិតទៅធ្វើប្រតិបត្តិការជាមួយប្រព័ន្ធអនឡាញដែលមានភាពសង្ស័យណាមួយ ឬ មានភាពមិនប្រក្រតីឡើយ ឬ មិនស្គាល់ច្បាស់។

18.1.2. ត្រូវស្គាល់ និងដឹងពីប្រភេទអាជីវកម្មតាមអនឡាញ និងអាសយដ្ឋានគេហទំព័រ/វេបសាយត៍ដែលទិញទំនិញ/សេវាកម្ម ជាទីគួរឱ្យទុកចិត្តបាន មុនបើកបង្ហាញព័ត៌មានលម្អិតនៃបណ្ណនិម្មិត។

18.1.3. សូមកុំផ្តល់ព័ត៌មានបណ្ណនិម្មិតដូចជា លេខបណ្ណនិម្មិត កាលបរិច្ឆេទផុតកំណត់ និងលេខ CVV ទៅឱ្យនរណាម្នាក់ជាដាច់ខាត ដោយសារព័ត៌មានទាំងនេះអាចប្រើប្រាស់ដើម្បីធ្វើប្រតិបត្តិការទិញទំនិញ/សេវាតាមអនឡាញបាន។

18.1.4. លោក-លោកស្រី ត្រូវធានាថា ទូរស័ព្ទ ឬ ឧបករណ៍អេឡិចត្រូនិក ដែលលោក-លោកស្រីប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល មានសុវត្ថិភាព និងមិនត្រូវបាន Root, Jailbreak ឬ ត្រូវបានដំឡើងកម្មវិធីដែលអាចបង្កហានិភ័យផ្នែកសុវត្ថិភាពឡើយ។

18.1.5. ក្នុងករណីដែលលោក-លោកស្រី សង្ស័យថា ព័ត៌មានប័ណ្ណ ឬ គណនីរបស់ខ្លួនត្រូវបានលួចប្រើប្រាស់ ឬ ត្រូវបានចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត លោក-លោកស្រី ត្រូវធ្វើការបង្ខាំង (Freeze) បណ្ណភ្លាមៗ និងជូនដំណឹងមកខេប៊ីប្រាសាក់ភ្លាមៗ។

18.1.6. លោក-លោកស្រីត្រូវជូនដំណឹងមកខេប៊ីប្រាសាក់ភ្លាមៗតាមរយៈលេខទូរស័ព្ទ ០២៣/០៨៦ ៩៩៩ ៩១១ ប្រសិនបើលោក-លោកស្រីសង្ស័យ ឬ កត់សម្គាល់ថា **ព័ត៌មានប័ណ្ណ** របស់លោក-លោកស្រីត្រូវបានគេដឹង ឬ ភ្លេច ឬ បាត់ ឬ ត្រូវបានលួច ឬ លោក-លោកស្រីអាចធ្វើការបង្ខាំងបណ្ណភ្លាមៗតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល បានដោយខ្លួនឯង។

18.2. សារបោកបញ្ឆោតតាមរយៈអ៊ីម៉ែល ឬ ទូរស័ព្ទ៖

18.2.1 សូមប្រុងប្រយ័ត្នការបោកបញ្ឆោតយកព័ត៌មាន តាមរយៈអ៊ីម៉ែល វេបសាយ កម្មវិធីដែលលោតផ្ទាំងមក (pop-up Windows) ឬ សារ SMS ដែលជាល្បិចឱ្យលោក-លោកស្រីបញ្ចេញព័ត៌មានសំខាន់ៗ ដូចជា៖ លេខបណ្ណនិម្មិត លេខកូដ CVV និង កាលបរិច្ឆេទផុតកំណត់បណ្ណនិម្មិត។ល។

18.2.2 ប្រសិនបើលោក-លោកស្រីទទួលបានអ៊ីម៉ែល ដែលស្នើសុំព័ត៌មានទាំងនេះ សូមលុបចោលជាបន្ទាន់ និងមិនត្រូវចុចភ្ជាប់បណ្តាញ (Link) ឬ បើកឯកសារភ្ជាប់ណាមួយ ដែលមាននៅក្នុងអ៊ីម៉ែលនោះឡើយ។

18.2.3 សូមលោក-លោកស្រីប្រុងប្រយ័ត្ន និងហាមផ្តល់ជាដាច់ខាតនូវព័ត៌មានបណ្ណនិម្មិត ក្នុងករណីមានបុគ្គលណាម្នាក់អះអាងថា ជាបុគ្គលិករបស់ខេប៊ីប្រាសាក់ ព្រោះខេប៊ីប្រាសាក់ មិនធ្វើការស្នើសុំលេខបណ្ណនិម្មិត លេខ CVV, លេខ OTP, ពាក្យសម្ងាត់ (Password) ឬ ព័ត៌មានសម្ងាត់ផ្សេងៗ តាមទូរស័ព្ទ អ៊ីម៉ែល សារ SMS ឬ បណ្តាញសង្គមឡើយ។

18.2.4 លោក-លោកស្រី ត្រូវប្រុងប្រយ័ត្នចំពោះការបោកប្រាស់តាមបណ្តាញសង្គម ការហៅទូរស័ព្ទក្លែងបន្លំ ការផ្ញើតំណភ្ជាប់ (Link) ក្លែងក្លាយ និងការស្នើសុំដំឡើងកម្មវិធីពីប្រភពមិនគួរឱ្យទុកចិត្តឡើយ។

18.2.5 ប្រសិនបើលោក-លោកស្រីមានចម្ងល់ ឬ ក៏មានមន្ទិលសង្ស័យលើវេបសាយ ឬ អ៊ីម៉ែលណាមួយ សូមទំនាក់ទំនងមក ខេប៊ីប្រាសាក់ តាមរយៈអ៊ីម៉ែល info@kbprasacbank.com.kh ឬ ទូរស័ព្ទលេខ ០២៣/០៨៦ ៩៩៩ ៩១១ ជាបន្ទាន់។

19. ការដោះស្រាយវិវាទលើប្រតិបត្តិការបណ្ណនិម្មិត

19.1. លោក-លោកស្រី ត្រូវជូនដំណឹងមកខេប៊ីប្រាសាក់ឱ្យបានឆាប់បំផុត បន្ទាប់ពីរកឃើញថាមានប្រតិបត្តិការមិនប្រក្រតី ឬ ប្រតិបត្តិការដែលមិនបានអនុញ្ញាត។

19.2. ខេប៊ីប្រាសាក់ នឹងធ្វើការពិនិត្យ និងស៊ើបអង្កេតលើប្រតិបត្តិការដែលមានវិវាទស្របតាមនីតិវិធី និងបទប្បញ្ញត្តិរបស់ VISA និងខេប៊ីប្រាសាក់។

19.3. រាល់ការស្នើសុំដោះស្រាយវិវាទលើប្រតិបត្តិការបណ្ណនិម្មិត រួមមាន ប្រតិបត្តិការគ្មានការអនុញ្ញាត ឬ ប្រតិបត្តិការមួយកើតឡើងច្រើនដង ឬ វិវាទផ្សេងទៀត លោក-លោកស្រី ត្រូវស្នើសុំមកខេប៊ីប្រាសាក់ឱ្យបានទាន់ពេល ដើម្បីខេប៊ីប្រាសាក់ធ្វើការពិនិត្យ និងដោះស្រាយឱ្យបានសមស្របតាមនីតិវិធី។

19.4. រាល់កម្រៃសេវាសម្រាប់ដំណើរការដោះស្រាយបណ្តឹងដែលត្រូវបានកំណត់ដោយ VISA ជាបន្ទុកចំណាយរបស់លោក-លោកស្រី។ ធនាគារនឹងជូនដំណឹងដល់លោក-លោកស្រីអំពីលក្ខខណ្ឌដែល VISA តម្រូវអោយបង់កម្រៃសេវានេះ។

19.5. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការបដិសេធការទាមទារសំណង ប្រសិនបើរកឃើញថា ការខាតបង់ ឬ ប្រតិបត្តិការមិនមានការអនុញ្ញាតកើតឡើងដោយសារការធ្វេសប្រហែស ការចែករំលែកព័ត៌មានសម្ងាត់ ឬ ការមិនអនុវត្តតាមលក្ខខណ្ឌសុវត្ថិភាពរបស់លោក-លោកស្រី។

20. សិទ្ធិ និងកាតព្វកិច្ចរបស់លោក-លោកស្រី

20.1. លោក-លោកស្រី ត្រូវធានាថាគ្រប់ព័ត៌មានដែលបានផ្តល់មក ខេប៊ីប្រាសាក់ ជាព័ត៌មានត្រឹមត្រូវ និង ថ្មីបំផុត។ ករណីលោក-លោកស្រី ផ្តល់ព័ត៌មានមិនពិត ឬ ក្លែងក្លាយ នោះ លោក-លោកស្រី ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់។

20.2. លោក-លោកស្រី ត្រូវធ្វើការត្រួតពិនិត្យកម្រៃសេវា និងព័ត៌មាននៃការទូទាត់ឱ្យបានត្រឹមត្រូវមុននឹងបញ្ជាប្រតិបត្តិការ។ រាល់ការបញ្ចូលព័ត៌មានខុស ឬ សមតុល្យលើស ឬ ខ្វះ ជាដើម ជាការទទួលខុសត្រូវទាំងស្រុងរបស់លោក-លោកស្រី។

20.3. លោក-លោកស្រី ត្រូវទទួលខុសត្រូវលើការប្រើប្រាស់បណ្ណនិម្មិត និងមិនត្រូវប្រើប្រាស់បណ្ណនិម្មិត ដើម្បីធ្វើប្រតិបត្តិការក្នុងគោលបំណងមិនស្របច្បាប់ជាតិ និងច្បាប់អន្តរជាតិឡើយ។

20.4. រាល់ការបាត់បង់ទឹកប្រាក់ក្នុងគណនីផ្ទាល់ខ្លួន ឬ គណនីរបស់អ្នកផ្សេង ដែលប្រព្រឹត្តដោយចេតនា ឬ អចេតនា ឬ ដោយការធ្វេសប្រហែស ឬ ដោយការសាកល្បងធ្វើប្រតិបត្តិការផ្សេងៗ ការលុកលុយរុករក ការកែបន្លំទិន្នន័យ ការលួចបន្លំដោយផ្ទាល់ ឬ ដោយប្រយោលតែម្នាក់ឯង ឬ ដោយមានការចូលរួមពីអ្នកដទៃ លោក-លោកស្រី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

20.5. លោក-លោកស្រី យល់ព្រមដោយឥតលក្ខខណ្ឌក្នុងការទូទាត់សំណងមក ខេប៊ីប្រាសាក់ ករណីមានការប្តឹងតវ៉ា ការទាមទារ ការទទួលខុសត្រូវ ការខាតបង់ ឬ ការចំណាយផ្សេងៗ ដែល ខេប៊ីប្រាសាក់ ទទួលរងទាក់ទងនឹងប្រតិបត្តិការតាមបណ្ណនិម្មិត ដោយការអនុវត្តបំពានរបស់ លោក-លោកស្រី លើលក្ខខណ្ឌនៃការប្រើប្រាស់បណ្ណនិម្មិត រួមទាំងការខកខានមិនបានចាត់វិធានការទប់ស្កាត់ ការធ្វើប្រតិបត្តិការដោយគ្មានការអនុញ្ញាត ឬ ប្រតិបត្តិការក្លែងបន្លំ។ល។

20.6. លោក-លោកស្រី ត្រូវជូនដំណឹងមក ខេប៊ីប្រាសាក់ ជាលាយលក្ខណ៍អក្សរឱ្យបានទាន់ពេលវេលា ក្នុងករណីមានការផ្លាស់ប្តូរលេខទូរស័ព្ទ អ៊ីម៉ែល និង/ឬ ព័ត៌មានផ្ទាល់ខ្លួនផ្សេងៗ ដែលបានផ្តល់មក ខេប៊ីប្រាសាក់។ រាល់ការខាតបង់ ឬ ការពន្យារពេលផ្សេងៗដែលអាចកើតមកពីការខកខានមិនបានជូនដំណឹងមក ខេប៊ីប្រាសាក់ ជាការទទួលខុសត្រូវទាំងស្រុងរបស់ លោក-លោកស្រី។

20.7. លោក-លោកស្រី មិនត្រូវធ្វើប្រតិបត្តិការណាមួយដែលខុសច្បាប់ ឬ សកម្មភាពអាជីវកម្មណាមួយ ដែលត្រូវបានហាមឃាត់ឡើយ។

20.8. លោក-លោកស្រី មានសិទ្ធិក្នុងការផ្ទៀងផ្ទាត់ព័ត៌មាននៅក្នុង របាយការណ៍គណនីរបស់ខ្លួន និងសាកសួរមក ខេប៊ីប្រាសាក់ ក្នុងករណីមានភាពមិនប្រក្រតីណាមួយកើតឡើង។

20.9. លោក-លោកស្រី ត្រូវធានាថា លោក-លោកស្រីនឹងមិនប្រើប្រាស់ប័ណ្ណនិម្មិតភ្ជាប់ជាមួយគណនីដែលលោក-លោកស្រីមិនមានសិទ្ធិនៅក្នុងគណនី ដើម្បីធ្វើប្រតិបត្តិការឡើយ។ ករណីមានវិវាទកើតឡើងលើគណនីដែលមិនមានសិទ្ធិ លោក-លោកស្រី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

21. សិទ្ធិ និងកាតព្វកិច្ចរបស់ខេប៊ីប្រាសាក់

21.1. ខេប៊ីប្រាសាក់ មានសិទ្ធិផ្ទៀងផ្ទាត់ព័ត៌មានរបស់ លោក-លោកស្រី និងសម្រេចក្នុងការផ្តល់ជូនប័ណ្ណនិម្មិតដល់ លោក-លោកស្រី។

21.2. ខេប៊ីប្រាសាក់ នឹងអនុវត្តតាមការបញ្ជាលើប្រតិបត្តិការទូទាត់តាមរយៈប័ណ្ណនិម្មិតរបស់លោក-លោកស្រី ប៉ុន្តែ ខេប៊ីប្រាសាក់ មិនទទួលខុសត្រូវ ក្នុងករណីដែល លោក-លោកស្រី បានបញ្ចូលព័ត៌មានខុស ឬ សមតុល្យលើស ឬ ខ្វះ ជាដើម។

21.3. ខេប៊ីប្រាសាក់ មានសិទ្ធិសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត បង្ខាំង ឬ បញ្ឈប់ការប្រើប្រាស់ប័ណ្ណនិម្មិត របស់ លោក-លោកស្រី ដោយយោងលើបទប្បញ្ញត្តិច្បាប់ ឬ ដីកាពីតុលាការ ឬ ការធ្វើប្រតិបត្តិការមិនស្របច្បាប់ណាមួយ។

21.4. ខេប៊ីប្រាសាក់ នឹងរក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់ លោក-លោកស្រី លើកលែងមានការយល់ព្រមពី លោក-លោកស្រី ឬ ច្បាប់តម្រូវ ឬ មានដីកាពីតុលាការបង្គាប់ឱ្យបង្ហាញព័ត៌មានសម្ងាត់ទាំងនោះ។

21.5. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកំណត់ចំនួនដង និងចំនួនទឹកប្រាក់ សម្រាប់ការប្រើប្រាស់ប័ណ្ណនិម្មិត។

21.6. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែ ឬ អនុវត្តការយកកម្រៃសេវាប្រចាំឆ្នាំ/ប្រចាំខែ និង/ឬ កម្រៃសេវាពាក់ព័ន្ធលើការប្រើប្រាស់ និង/ឬ ធ្វើប្រតិបត្តិការតាមរយៈប័ណ្ណនិម្មិត អាស្រ័យលើលក្ខខណ្ឌ និងស្ថានភាពអាជីវកម្មជាក់ស្តែង។

21.7. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការធ្វើបច្ចុប្បន្នភាពជាប្រចាំលើប័ណ្ណនិម្មិត ដូចជា៖

- ដាក់បន្ថែមមុខងារប្រតិបត្តិការថ្មីៗ ដោយយោងទៅតាមនិន្នាការទីផ្សារ និង/ឬ ការប្រែប្រួលបច្ចេកវិទ្យា ឬ
- លុប ឬ ផ្អាកជាបណ្តោះអាសន្នលើមុខងារណាមួយ ប្រសិនបើមានបញ្ហាបច្ចេកទេសណាមួយកើតឡើង ដែលអាចមានផលប៉ះពាល់ដល់ប្រព័ន្ធធនាគារ ឬ ក្នុងគោលបំណងថែទាំប្រព័ន្ធ ឬ ផ្សេងៗ។

21.8. ប្រសិនបើ ប័ណ្ណនិម្មិត របស់លោក-លោកស្រី មិនអាចប្រើប្រាស់បានដោយករណីប្រធានសក្តិ ខេប៊ីប្រាសាក់ នឹងជួយដល់ លោក-លោកស្រី ក្នុងការរកដំណោះស្រាយ ឬ ផ្តល់ជំនួយការចាំបាច់ណាមួយយោងលើហេតុផលជាក់ស្តែង ប៉ុន្តែខេប៊ីប្រាសាក់មិនទទួលខុសត្រូវទៅលើហេតុការណ៍ទាំងនោះទេ។

21.9. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការផ្អាកប្រតិបត្តិការពេលមានបញ្ហាផ្សេងៗ និងពេលមានការចាំបាច់ជាដើម។

21.10. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការបដិសេធ ផ្អាក បង្ខាំង ឬ កំណត់ប្រតិបត្តិការជាបណ្តោះអាសន្ន ប្រសិនបើរកឃើញ ឬ សង្ស័យថាមានសកម្មភាពក្លែងបន្លំ ការវាយប្រហារតាមប្រព័ន្ធអេឡិចត្រូនិក (Cyber Attack) ការប្រើប្រាស់ខុសប្រក្រតី ឬ សកម្មភាពដែលអាចបង្កហានិភ័យដល់អតិថិជន និងខេប៊ីប្រាសាក់។

21.11. ខេប៊ីប្រាសាក់ អាចស្នើសុំឯកសារ ឬ ព័ត៌មានបន្ថែមពីលោក-លោកស្រី ដើម្បីផ្ទៀងផ្ទាត់ប្រតិបត្តិការ ក្នុងករណីដែលប្រតិបត្តិការនោះត្រូវបានចាត់ទុកថាមានហានិភ័យខ្ពស់ ឬ មានលក្ខណៈមិនប្រក្រតី។

22. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

អនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ខេប៊ីប្រាសាក់អាចនឹងពន្យារពេល ឬ មិនធ្វើប្រតិបត្តិការជូន លោក-លោកស្រី ប្រសិនបើខេប៊ីប្រាសាក់ មានការជឿជាក់ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

1). ខេប៊ីប្រាសាក់ មានការសង្ស័យចំពោះប្រភពដើមនៃប្រាក់បញ្ញើនោះ
2). ប្រតិបត្តិការ ឬ គណនីនោះមានទំនាក់ទំនង ឬ ពាក់ព័ន្ធដោយផ្ទាល់ ឬ ដោយប្រយោលជាមួយនឹងសកម្មភាពល្មើសច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ច្បាប់អន្តរជាតិ
3). មានការបង្គាប់បញ្ជាពីតុលាការ ឬ ធនាគារជាតិ នៃ កម្ពុជា។ល។

23. ច្បាប់គ្រប់គ្រង

លក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណនិម្មិតនេះ ត្រូវបានគ្រប់គ្រង និងបកស្រាយដោយយោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

24. ស្វ័យភាពនៃបញ្ញត្តិ

ប្រសិនបើប្រការណាមួយនៃលក្ខខណ្ឌប្រើប្រាស់នេះ មិនអាចអនុវត្តបាន ឬ គ្មានសុពលភាពតាមផ្លូវច្បាប់ ប្រការទាំងនោះនឹងអស់សុពលភាពត្រឹមកម្រិតដែលប្រការនោះមិនអាចអនុវត្តបាន ឬ អសុពលភាពនៃប្រការនោះតែប៉ុណ្ណោះ ចំណែកប្រការផ្សេងៗទៀតនៃលក្ខខណ្ឌប្រើប្រាស់នេះនៅតែបន្តមានសុពលភាពអនុវត្តដដែល៕